ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១៥១ សហវ.ប្រក.៥៣

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦

# ប្រកាសអន្តរក្រសួង

## ស្តីពី

## អាករបំណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព

---

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## និង

## រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជសរកម ០៣៩៧-០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- អនុវត្តតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យ ហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និង អង្គការសាធារណៈរដ្ឋបាល
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យ សាធារណៈ
- បានឃើញប្រកាសរួមលេខ ៥៦ សកបយ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីអាករប័ណ្ណការងារ និង សៀវភៅ ការងារ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមសារាចរណែនាំលេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីវដ្តទេយ្យចំណូល
- អនុវត្តតាមសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា
- បានឃើញមតិយល់ព្រមរបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០៦ លើលិខិតលេខ ៦៩៥ សហវ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញការចាំបាច់របស់ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

## សំ រេ ច

**ប្រការ ១ :** អនុញ្ញាតឱ្យយកអាករលើប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ចំពោះកម្មករ និយោជិត ជនជាតិខ្មែរ និង ជនបរទេស ដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២ :** អាករលើប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវបានកំណត់ដូចខាងក្រោមៈ

ក- អាករលើប័ណ្ណការងារ និងសៀវភៅការងារ ចំពោះ កម្មករ និយោជិតជនជាតិខ្មែរម្នាក់ៗ ត្រូវកំណត់ តំលៃ ២ ៥០០ (ពីរពាន់ប្រាំរយ) រៀល ។ អាករនេះ ត្រូវបានកំណត់ឱ្យបង់ម្តងគត់ នៃអាជីពការងារ ។

ខ- អាករលើប័ណ្ណការងារ និង សៀវភៅការងារជនបរទេស ត្រូវបង់ប្រចាំឆ្នាំៈ

- អាករប្រចាំឆ្នាំប្រតិទិន នៃប័ណ្ណការងារ និង សៀវភៅការងារជនបរទេសម្នាក់ៗ ដែលចូលមកស្នាក់នៅមានរយៈពេលកំណត់មួយច្បាស់លាស់ ដើម្បីប្រកបមុខរបរអ្វីមួយ ឬ ធ្វើអ្វីមួយយកប្រាក់ឈ្នួល ត្រូវបានកំណត់តំលៃ ១០០ (មួយរយ) ដុល្លារអាមេរិក ក្នុងប័ណ្ណការងារ និង សៀវភៅការងារមួយ ។
- អាករប្រចាំឆ្នាំប្រតិទិន នៃប័ណ្ណការងារ និង សៀវភៅការងារជនបរទេសម្នាក់ៗ ដែលមករស់នៅអចិន្ត្រៃយ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពីអាយុ ១៨ ឆ្នាំ ឡើងទៅ ត្រូវបានកំណត់តំលៃ ៥០ (ហាសិប) ដុល្លារអាមេរិក ក្នុងប័ណ្ណការងារ និង សៀវភៅការងារមួយ ។

គ- ចំពោះជនបរទេស ដែលមានប័ណ្ណការងារ និង សៀវភៅការងាររួចហើយ ត្រូវមានកាតព្វកិច្ចដាក់ពាក្យស្នើសុំពន្យារទិដ្ឋាការ អោយបានមុនដំណាច់ខែមីនា ជារៀងរាល់ឆ្នាំ ។

ឃ- ចំពោះកំរៃសេវាលើការពិនិត្យសុខភាព ដែលនិយោជកត្រូវបង់ ត្រូវបានកំណត់ ដូចខាងក្រោមៈ

- ចំពោះកម្មករ និយោជិតជនជាតិខ្មែរម្នាក់ៗ ត្រូវបានកំណត់ចំនួន ១២ ០០០ (ដប់ពីរពាន់) រៀល ។
- ចំពោះជនបរទេសម្នាក់ៗ ត្រូវបានកំណត់ចំនួន ១៥ (ដប់ប្រាំ) ដុល្លារអាមេរិក ។

ង- កម្មករ និយោជិតជនជាតិខ្មែរ និង ជនបរទេស ដែលបានបង់អាករប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវបានទទួលបង្កាន់ដៃបង់ប្រាក់ ដែលចេញដោយនាយកដ្ឋានជំនាញ នៃក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ដោយអនុវត្តតាមច្បាប់ និង លិខិតបទដ្ឋានជាធរមាន ។

**ប្រការ ៣ :** កម្មករ និយោជិតជនជាតិខ្មែរ និង ជនបរទេស ប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនបានបង់អាករប័ណ្ណការងារ និង សៀវភៅការងារ ត្រូវផ្តន្ទាទោសទៅតាមច្បាប់ការងារ នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ៤ :** ការបង់ប្រាក់ និង ការទទួលប្រាក់ចំណូលពីអាករប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវអនុវត្តតាមរយៈរដ្ឋលេខាធិការចំណូល ឬរដ្ឋលេខាធិការចំណូលរងនៅក្រសួង និង នៅមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ។

**ប្រការ ៥ :** ក- ការគ្រប់គ្រងចំណូលពីអាករប័ណ្ណការងារ សៀវភៅការងារ និង កំរៃសេវាពិនិត្យសុខភាព ត្រូវអនុវត្តតាមនិតិវិធី នៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រាក្នុងជំពូក ២១ ប្រការ ០៣ កថាខ័ណ្ឌ ៣០ សំរាប់ឆ្នាំ ២០០៦ និងកត់ត្រាក្នុងជំពូក គណនី អនុគណនី តាមមាតិកាថវិកាថ្មីដែលនឹងកែប្រែទៅតាមកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

ខ- ចំណូល ដែលប្រមូលបានដោយ ក្រសួង និង មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត-ក្រុង រដ្ឋលេខាធិការចំណូល ត្រូវបង់ដោយត្រង់ចូលក្នុងគណនីរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង នៅធនាគារជាតិ ឬ សាខាធនាគារខេត្ត-ក្រុង ។

គ- ក្រសួង និង មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ត្រូវបូកសរុបធ្វើរបាយការណ៍ ចំណូលពីអាករប័ណ្ណការងារ សៀវភៅការងារ និងកំរៃសេវាពិនិត្យសុខភាពប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

**ប្រការ ៦ :** ក- ចំណូលពីអាករប័ណ្ណការងារ និង សៀវភៅការងារ ត្រូវបង់ ១០០% ចូលថវិការដ្ឋ ។ ក្នុងនោះ ៧០% ជាអត្ថប្រយោជន៍ថវិកាជាតិ និង អនុញ្ញាតឱ្យក្រសួង និងមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ដកវិញចំនួន៣០% សំរាប់ឧបត្ថម្ភដល់មន្ត្រីក្រោមឱវាទ ជាការលើកទឹកចិត្ត ក្នុងការបំពេញភារកិច្ចប្រមូលចំណូលនេះ ។

- ការដកចំណែក ៣០% របស់ក្រសួង និងមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ត្រូវធ្វើតាមរយៈអាណត្តិបើកប្រាក់ ដោយមានភ្ជាប់មកជាមួយ នូវរបាយការណ៍បូកសរុបចំណូល និងសលាកប័ត្រចំណូលថវិកាជាតិ ហើយកត់ត្រានៅក្នុង ជំពូក ១០ ប្រការ ០២ កថាខ័ណ្ឌ ០៣ វាក្យខ័ណ្ឌ ០៧ សំរាប់ឆ្នាំ ២០០៦ និងកត់ត្រាក្នុងជំពូក គណនី អនុគណនី តាមមាតិកាថវិកាថ្មីដែលនឹងកែប្រែទៅតាមកម្មវិធីកំណែទំរង់ហិរញ្ញវត្ថុសាធារណៈ ។

- ការដកចំណែក ៣០% របស់ក្រសួង និងមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត-ក្រុង ត្រូវចាប់អនុវត្តពីឆ្នាំ ២០០៦ តទៅ ។

ខ- ដោយឡែកចំណូលពីកំរៃសេវាពិនិត្យសុខភាព ត្រូវបានកំណត់ :

- ៥៣% សំរាប់ជំនួយបង្កើនគុណភាពសេវាកម្ម ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ជួសជុលតូច
- ៤៥% សំរាប់ចំណាយឧបត្ថម្ភមន្ត្រីរាជការ និយោជិត
- ២% សំរាប់បង់ចូលថវិកាជាតិ ។

**ប្រការ ៧ :** - *ការបោះពុម្ព ប័ណ្ណការងារ សៀវភៅការងារ វិញ្ញាបនប័ត្រពិនិត្យសុខភាព និង ប័ណ្ណចំណូល* ត្រូវស្ថិតក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់គណៈកម្មការអន្តរក្រសួង រវាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ ។

- ប័ណ្ណការងារ សៀវភៅការងារ វិញ្ញាបនប័ត្រពិនិត្យសុខភាព និង ប័ណ្ណចំណូល ត្រូវមានលេខរៀងត្រឹមត្រូវ និង មានលក្ខណៈសំគាល់ដោយឡែក រវាងកម្មករ និយោជិតជនជាតិខ្មែរ និង ជនបរទេស ដើម្បីងាយស្រួលគ្រប់គ្រង ។

**ប្រការ ៨ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

**ប្រការ ១០ :** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
គាត ឈន់

រដ្ឋមន្ត្រី
ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

**ចម្លងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធិសភា និង អធិការកិច្ច
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់សាលាខេត្ត-ក្រុង

  " ដើម្បីជូនជ្រាប "

- ដូចប្រការ ៩ " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ